# គម្រោងគាំទ្រសេវាអប់រំកុមារនៅតំបន់ដាច់ស្រយាល

## (អេស្កាប់)

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

## បញ្ជីសេវាកម្ម



# លើកកំពស់បរិស្ថានរៀនសូត្របែបសាលាកុមារមេត្រី

| សមាសភាគ | លរ | បញ្ហា | បរិយាយសកម្មភាព | ធនធាន និងតម្លៃឯកតា | |
|---|---|---|---|---|---|
| **សមាសភាគទី ១ និង ទី៤ : កុមារទាំងអស់បានចូលរៀន និងការធ្វើអោយមានសមធម៌** | 1 | ❖ អត្រាចុះឈ្មោះចូលរៀនទាប<br>❖ អត្រាបោះបង់ខ្ពស់ | **អាហារូបករណ៍សិស្សបឋមសិក្សា :** សហគមន៍ក្នុងមូលដ្ឋាន *បង្កើត* គណៈកម្មការដើម្បីអង្កេតកំណត់រកកុមារក្រីក្រ ដោយប្រើឧបករណ៍អង្កេតជាស្តង់ដារមួយ ។ គេអាចកំណត់កុមារដែលក្រីក្រដោយផ្អែកលើពិន្ទុនៃឧបករណ៍អង្កេតនេះ ។ ការបែងចែកកញ្ចប់អាហារូបករណ៍ទៅដល់កុមារក្រីក្រដែលបាន ជ្រើសរើសត្រូវ ធ្វើឡើង 3 ដង ក្នុងមួយឆ្នាំ ។ | ❖ អ្នកអង្កេតស្ម័គ្រចិត្ត : $1 /ម្នាក់<br>❖ សម្ភារសំរាប់អង្កេត $5/សាលា<br>❖ សោហ៊ុយធ្វើដំណើរស្រាវជ្រាវ $1 /ម្នាក់<br>❖ សម្ភារអាហារូបករណ៍ $8 /សិស្សម្នាក់ |  |
| | 2 | ❖ អត្រាចុះឈ្មោះចូលរៀនទាប<br>- អត្រាបោះបង់ខ្ពស់<br>- អត្រាឆ្លងភូមិសិក្សាទាប | **អាហារូបករណ៍សិស្សមធ្យមសិក្សា :** បង្កើតគណៈកម្មការដែលមានតំណាងមកពីមធ្យមសិក្សា កម្រងសាលា និងសហគមន៍ ។ កុមារត្រូវបានលើកទឹកចិត្តអោយដាក់ពាក្យសុំអាហារូបករណ៍ ។ គណៈកម្មការមូលដ្ឋានចុះធ្វើអង្កេត ដោយប្រើទម្រង់អង្កេតតាមស្តង់ដារ ។ បេក្ខជនត្រូវបានជ្រើសរើសដោយផ្អែកតាមពិន្ទុនៃទម្រង់នេះ ។ គណៈកម្មការបែងចែកកញ្ចប់អាហារូបករណ៍ដែលមានលក្ខណៈស្តង់ដារយ៉ាងតិច ៣ ដងក្នុងមួយឆ្នាំ ។ | ❖ អ្នកអង្កេតស្ម័គ្រចិត្ត<br>❖ សម្ភារសម្រាប់អង្កេត<br>❖ ថវិកាសម្រាប់ធ្វើដំណើរ<br>❖ សម្ភារគាំទ្រអាហារូបករណ៍<br>(ថវិកាកណ្តាលពីអេស្កាប់) |  |
| | 3 | ❖ ពិការភាពជាឧបសគ្គរារាំងមិនអោយកុមារបានចូលរៀន<br>-ពិការភាពរារាំងដល់ការចូលរៀន | **ការព្យាបាលកាយសម្បទាដល់កុមារពិការ**<br>ការអង្កេតមូលដ្ឋាន *កំណត់រក* កុមារពិការ ឬ កុមារដែលមានជំងឺ រ៉ាំរ៉ៃ និង នាំទៅកន្លែងផ្តល់សេវាព្យាបាល ។ | -អ្នកអង្កេត<br>-ថវិកាធ្វើដំណើរ<br>**(ថវិកាកណ្តាលពីអេស្កាប់)** |   |

| | | | | | |
|---|---|---|---|---|---|
| | 4 | ❖ បញ្ហាពិសេសដែលរារាំងមិនអោយកុមារបានចូលរៀន | **ការគាំទ្រកុមារ ជួយកុមារ សំរាប់កុមារងាយរងគ្រោះ** សាលា*កំណត់* កុមារដែលជួបនឹងការប្រថុយបោះបង់ (ឧ.កុមារពិការ កុមាររៀនខ្សោយ កុមារជនជាតិភាគតិច ) ហើយផ្តល់ការជួយជ្រោមជ្រែងពិសេស (អ្នកជួយដល់មិត្តភក្តិ ផ្លូវទេរ ការបង្រៀនបន្ថែមនៅផ្ទះ ) ដើម្បីរៀននៅសាលា | ❖ សិក្ខាសាលាបំប៉នអ្នកចុះអង្កេត<br>❖ ថវិកាជំនួយមួយភាគតូចសំរាប់ជួយដល់កុមារដែលមានតំរូវការពិសេស<br>**(ថវិកាកណ្តាលពីអេស្កាប់)** | <br> |
| | 5 | ❖ ការរៀនមិនចប់ធ្វើអោយអត្រាបញ្ចប់ការសិក្សាមានអត្រាទាប | **គ្រូសហគមន៏:** គណៈកម្មការកំរងសាលា គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នា ជ្រើសរើសសមាជិកសហគមន៏ដើម្បធ្វើជាគ្រូនៅតាមសាលា។ គ្រូទទួលបានកម្មវិធីបំប៉នពីកម្មវិធីអេស្កាប់ ។ | ❖ គ្រូស្ម័គ្រចិត្ត<br>❖ សម្ភារសំរាប់បង្រៀន<br>❖ សម្ភារថ្នាក់រៀន<br>❖ ប្រាក់ឧបត្ថម្ភគ្រូ<br>(ថវិកាកណ្តាលពីអេស្កាប់)<br>❖ ដំណើរការជ្រើសរើស $30/កម្រង |  |
| | 6 | ❖ ខ្វះបង្គន់អនាម័យបង្អាក់វត្តមានរបស់សិស្សស្រី | **បង្គន់អនាម័យ និងទឹកស្អាតៈ** សាលារៀនទាំងឡាយជីកអណ្តូង និង សាងសង់បង្គន់ដើម្បីសំរួលដល់ ការចូលរៀនរបស់កុមារី ។ | ❖ សម្ភារសាងសង់ $250/បង្គន់<br>❖ សម្ភារសាងសង់ $250/អណ្តូង |   |

| | | | | | |
|---|---|---|---|---|---|
| | 7 | ❖ អត្រាកុមារីបោះបង់ខ្ពស់<br>❖ អត្រាកុមារីអវត្តមានខ្ពស់ | **បំណិនជីវិតសម្រាប់កុមារីងាយរងគ្រោះ** (គេហកិច្ចកុមារី) គណៈកម្មការមូលដ្ឋានកំណត់រកសាលាទាំងឡាយណានៅក្នុងកម្រង ដែលមានអត្រាកុមារីបោះបង់ខ្ពស់ និងរៀបចំថ្នាក់បំណិនជីវិតពិសេសមួយ សម្រាប់កុមារីដែល មានប្រវត្តិបោះបង់ការសិក្សា និងអវត្តមានច្រើន។ វត្តមានអាចមានឡើងវិញជាមួយកម្មវិធីបំណិនជីវិត ផ្នែកដាំស្ល និងដេរប៉ាក់។ | ❖ សម្ភារសម្រាប់បង្រៀន $200/ក្រុម (២៥នាក់)<br>❖ ប្រាក់ឧបត្ថម្ភគ្រូ $0.5/ម៉ x ៤ម៉/សប្តាហ៍ x ១៨សប្តាហ៍<br>❖ ថវិកាតាមដានសិស្សអវត្តមានដល់ផ្ទះ $0.75/ម្តង x ៣ដង/ខែ x ៤ខែកន្លះ<br>❖ តម្រង់ទិសឪពុកម្តាយ $5/សាលា x ២ដង/ឆ្នាំ<br>- ថវិកាតាមដានគ្រូបង្រៀន $1/ខែ x ៤ខែកន្លះ |  |
| | 8 | ❖ អត្រាកុមារីបោះបង់ខ្ពស់<br>❖ អត្រាកុមារីអវត្តមានខ្ពស់ | **បំណិនជីវិតសម្រាប់កុមារាងាយរងគ្រោះ** (ជាងឈើ និងកំបោរ) គណៈកម្មការមូលដ្ឋានកំណត់រកសាលា ទាំងឡាយណានៅក្នុងកម្រង ដែលមានអត្រាកុមារាបោះបង់ខ្ពស់ និងរៀបចំថ្នាក់បំណិនជីវិតពិសេសមួយ សម្រាប់កុមារាដែលមានប្រវត្តិបោះបង់ការសិក្សា និងអវត្តមានច្រើន។ វត្តមានអាចមានឡើងវិញជាមួយកម្មវិធីបំណិនជីវិត ជាងឈើ និងជាងកំបោរ។ | ❖ សម្ភារសម្រាប់បង្រៀន $200/ក្រុម (២៥នាក់)<br>❖ ប្រាក់ឧបត្ថម្ភគ្រូ $0.5/ម៉ x ៤ម៉/សប្តាហ៍ x ១៨សប្តាហ៍<br>❖ ថវិកាតាមដានសិស្សអវត្តមានដល់ផ្ទះ $0.75/ម្តង x ៣ដង/ខែ x ៤ខែកន្លះ<br>❖ តម្រង់ទិសឪពុកម្តាយ $5/សាលា x ២ដង/ឆ្នាំ<br>ថវិកាតាមដានគ្រូបង្រៀន $1/ខែ x ៤ខែកន្លះ |  |

| | | | | | |
|---|---|---|---|---|---|
| | 9 | ❖ អត្រាចូលរៀនទាប ដោយសារតែខ្វះសាលា<br>❖ សាលាមិនគ្រប់កំរិតថ្នាក់ កាត់បន្ថយអត្រាបញ្ចប់ការសិក្សា | **សាលាឆ្លងកាត់** សាលារៀនទទួលថវិកា ដើម្បីកសាងអាគារឆ្លងកាត់អោយបានទាន់ពេល និងចំណាយថវិកាតិច ដើម្បីសង្គ្រោះការអប់រំទាន់ពេលវេលា តាមតំបន់ដែលមិនមានសាលារៀនសោះ រឺ សម្រាប់បង្កើនកំរិតថ្នាក់។ អន្តរាគមនេះ មានបំណងដើម្បីជួយក្នុងអន្តរការ ទំរាំមានអាគារត្រឹមត្រូវ។ | ❖ សម្ភារសាងសង់ (ថវិកាកណ្តាលពីអេស្កាប់)<br>- កំលាំងពលកម្ម ពីសហគមន៍ |  |
| | 10 | ❖ អត្រាត្រួតថ្នាក់ខ្ពស់<br>❖ ថ្នាក់រៀនមានសិស្សច្រើនរារាំង ដល់ការប្រុងបយ័ត្នរបស់សិស្ស ដែលត្រូវការជំនួយពិសេស | **ការបំប៉នសិស្សរៀនយឺតតាមភូមិ**<br>សាលារៀនផ្តល់ឱកាសដល់កុមារដែលធ្លាក់នៅឆមាសទី 1 ដោយ អោយពួកគេបានចូលរៀនជាមួយគ្រូនៅក្នុងភូមិរបស់ពួកគេ ដើម្បីអោយពួកគេទទួលបាននូវការជួយជាពិសេសដល់ការរៀនសូត្ររបស់គេ ។ | ❖ គ្រូឧទ្ទេស<br>❖ សម្ភារសំរាប់បង្រៀន<br>❖ សម្ភារសំរាប់ថ្នាក់រៀន<br>❖ ប្រាក់ឧបត្ថម្ភគ្រូ<br>($81/សិស្ស១ក្រុម (២០នាក់) |  |
| **សមាសភាគទី២ ៖ ការសិក្សាប្រកបដោយបរិយាប័ន្នភាព** | 11 | ❖ អត្រាត្រួតថ្នាក់ខ្ពស់<br>❖ ថ្នាក់រៀនមានសិស្សច្រើនរារាំង ដល់ការប្រុងបយ័ត្នរបស់សិស្ស ដែលត្រូវការជំនួយពិសេស | **ការបំប៉នសិស្សរៀនយឺតតាមផ្ទះ**<br>សាលារៀនផ្តល់ឱកាសដល់កុមារដែលធ្លាក់នៅឆមាសទី 1 ដោយ អោយពួកគេបានរៀនជាមួយគ្រូនៅក្នុងផ្ទះរបស់ពួកគេ ដើម្បីអោយពួកគេទទួលបាននូវការជួយជាពិសេសដល់ការរៀនសូត្ររបស់គេ ។ | ❖ គ្រូឧទ្ទេស<br>❖ សម្ភារសំរាប់បង្រៀន<br>❖ សម្ភារសំរាប់ថ្នាក់រៀន<br>❖ ប្រាក់ឧបត្ថម្ភគ្រូ<br>❖ សោហ៊ុយធ្វើដំណើរគ្រូ<br>($81/សិស្ស១ក្រុម (២០នាក់) |  |
| | 12 | ❖ អគារដែលមានលក្ខណៈទ្រុឌទ្រោមជាកត្តារាំងស្ទះដល់ការកែលំអវិធីសាស្ត្របង្រៀន | **ការកែលំអ ហេដ្ឋារចនាសម្ព័ន្ធ:** សាលារៀននានា *ជួសជុល* អគារដែលមានស្រាប់ និង ដាក់ទ្វារ បង្អួច ។ល។ វាចាំបាច់ដើម្បីធានា សម្ភារសិក្សានៅក្នុងថ្នាក់រៀនអោយមានសុវត្ថិភាព ។ | ❖ សម្ភារសាងសង់ (ថវិកាកណ្តាលពីអេស្កាប់) |  |

| | | | | | |
|---|---|---|---|---|---|
| | | | | | |
| | 13 | ❖ កុមារដែលទើបនឹងចុះឈ្មោះចូលរៀនមិនទាន់បានរៀបចំខ្លួនដើម្បីសិក្សា | **បំពាក់បន្ទប់ថ្នាក់កុមារមេត្រី:** សាលារៀន *តុបតែងថ្នាក់រៀន* នៅថ្នាក់កុមារមេត្រី ដើម្បីអោយថ្នាក់រៀនទាំងនោះមានលក្ខណៈសមស្របសំរាប់បង្រៀន សកម្មភាពថ្នាក់កុមារមេត្រី ដែលជំរុញសកម្មភាពរៀន ព្រមទាំងសកម្មភាពគិតដោយវិភាគ និងច្នៃប្រឌិត ។ | ❖ សង្ហារឹម<br>❖ សម្ភារឧបទ្ទេស<br>❖ សម្ភាររៀន<br>❖ សម្ភារតុបតែងថ្នាក់រៀន<br>($110/បន្ទប់រៀន) |  |
| | 14 | ❖ ការអប់រំដែលមិនពាក់ព័ន្ធនឹង តំរូវការមូលដ្ឋាន | **បំណិនជីវិតដែលគាំទ្រនៅក្នុងមូលដ្ឋាន:** សាលារៀន *ផ្តល់អោយសិស្ស* នូវឱកាសទទួលបានមុខវិជ្ជា ជីវ:ដែលពួកគេចូលចិត្តរៀន ជាមួយគ្រូក្នុងសហគមន៍ ។ សាលារៀនជ្រើសរើសមនុស្សក្នុងសហគមន៍មកជួយបង្រៀន។ | ❖ សម្ភារសំរាប់បង្រៀន<br>$100/សាលា<br>- ប្រាក់ឧបត្ថម្ភសំរាប់គ្រូ<br>$0.5/ម៉ x ៤ម៉/សប្តាហ៍ x ១០សប្តាហ៍ x ៥គ្រូ<br>❖ បាក់ឧបត្ថម្ភអ្នកតាមដាន<br>- $1/សប្តាហ៍ x ១០សប្តាហ៍ |  |
| | 15 | ❖ ការអប់រំដែលមិនពាក់ព័ន្ធនឹង តំរូវការមូលដ្ឋាន | **វិធានការចំរុះថៃទាំដំណាំ (អាយ ភី អឹម)** សាលារៀន *ផ្តល់អោយសិស្ស* នូវឱកាសទទួលបានការសិក្សាពីការអនុវត្តបរិស្ថានកសិកម្មសុវត្ថិភាព ដែលជៀសវាងការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិត។ សាលារៀនជ្រើសរើសគ្រូម្នាក់ និង មនុស្សក្នុងសហគមន៍ម្នាក់ ។ | ❖ គ្រូបង្រៀន និងសហគមន៍<br>❖ ស្រែ<br>❖ សម្ភារសិក្សា<br>❖ ប្រាក់ឧបត្ថម្ភគ្រូបង្រៀន២នាក់<br>($400/ក្រុមសិស្ស (៣០នាក់) |  |

| | | | | | |
|---|---|---|---|---|---|
| | 16 | ❖ ការអប់រំមិនពាក់ព័ន្ធទៅនឹងតំរូវការពិសេសរបស់កុមារ ដែលភាសាទី 1 របស់គេពុំមែនជាភាសាខ្មែរ | **អ្នកសម្របសម្រួលភាសា:** នៅក្នុងសាលារៀនដែលមានជនជាតិភាគតិចច្រើន សាលារៀន *ជ្រើសរើស* អ្នកជំនួយការក្នុងមូលដ្ឋានដែលចេះនិយាយភាសាជនជាតិ ដើម្បីជួយដល់គ្រូបង្រៀនរបស់រដ្ឋ ក្នុងការបង្រៀនកុមារជនជាតិភាគតិច ដែលមិនចេះភាសាខ្មែរបានល្អ ។ | ❖ អ្នកស្ម័គ្រចិត្តពីសហគមន៏<br>❖ គ្រូឧទ្ទេស<br>❖ ប្រាក់ឧបត្ថម្ភសំរាប់គ្រូ<br>( ថវិកាកណ្តាលពីអេស្កាប់) |  |
| | 17 | ❖ សាលារៀនមានសិស្សតិចពេក | **រៀបចំថ្នាក់គួបៈ**<br>នៅក្នុងសាលារៀនដែលមានសិស្សតិចពេក នៅតាមកំរិតថ្នាក់នីមួយៗ គ្រូបង្រៀន *រៀន* ពីវិធីបង្រៀនថ្នាក់គួប ដើម្បីអោយសាលារៀនទាំងឡាយអាចបើកបង្រៀនថ្នាក់គួបបាន។ | ❖ គ្រូឧទ្ទេស ( អេស្កាប់)<br>❖ សម្ភារសំរាប់បង្រៀន $20/គ្រូម្នាក់ |  |
| | 18 | ❖ ការអប់រំមិនពាក់ព័ន្ធនឹងតម្រូវការក្នុងមូលដ្ឋាន | **បណ្ណាល័យ:** សាលារៀន *រៀបចំ* បន្ទប់អានដើម្បីអោយកុមារមានឱកាសអានសៀវភៅដែលពួកគេចូលចិត្ត ដើម្បីពង្រឹងបំណិនអំណានរបស់ពួកគេ។ | ❖ តុ $35/មួយ<br>❖ ទូមុខពីរ $35/មួយ<br>❖ សៀវភៅ $125/កំប្លេ<br>❖ កម្រាល $45/មួយបន្ទប់<br>❖ សម្ភារតុបតែង $20/បណ្ណា |  |
| | 19 | ❖ ការបង្រៀននៅក្នុងថ្នាក់ពុំមានប្រសិទ្ធិភាព | **កសាងសមត្ថភាពគ្រូថ្នាក់កុមារមេត្រី** សាលារៀន ជ្រើសរើសគ្រូស្មគ្រ័ចិត្ត ដើម្បីរៀបចំថ្នាក់កុមារមេត្រី។ គ្រូបង្រៀនទទួលការបំប៉ន ៨ ថ្ងៃ នៅដើមឆ្នាំសិក្សា និងសិក្ខាសាលាបន្តបន្ទាប់ក្នុងឆ្នាំសិក្សា។ | ❖ គ្រូឧទ្ទេស<br>❖ សម្ភារសំរាប់បង្រៀន<br>❖ ប្រាក់ឧបត្ថម្ភសិក្ខាកាម<br>❖ ឯកសារបង្រៀន និងរៀន<br>( ថវិកាកណ្តាលអេស្កាប់) |  |

| | | | | | |
|---|---|---|---|---|---|
| | 20 | ❖ ការអប់រំមិនពាក់ព័ន្ធទៅនឹងតម្រូវការមូលដ្ឋាន | **ទស្សនៈកិច្ចសិក្សារបស់សិស្ស** សាលារៀនរៀបចំថ្ងៃទស្សនៈកិច្ចសិស្ស (សិស្ស ថ្នាក់ទី ៤ ទី៥ រឺ ទី៦) ទៅកាន់កន្លែងដែលមានប្រយោជន៏ក្នុងការអប់រំ (ឧ. ប្រាសាទបុរាណ រោងចក្រក្នុងស្រុក កន្លែងទឹកឈូ សារមន្ទីរ ។ល។) | ❖ គ្រូទទួលខុសត្រូវ $1.5/គ្រូម្នាក់<br>❖ អាហារថ្ងៃត្រង់សិស្ស $1/សិស្សម្នាក់<br>❖ ជួលឡាន $50/ឡានមួយ<br>❖ អាហារគ្រូ $1/គ្រូម្នាក់ |  |
| | 21 | ❖ ការអប់រំមិនពាក់ព័ន្ធទៅនឹងតម្រូវការមូលដ្ឋាន | **ទស្សនៈកិច្ចសិក្សារបស់បុគ្គលិកសាលារៀន និងសហគមន៏** កម្រងជ្រើសរើសបុគ្គលិកដែលមានប្រយោជន៏ទៅទស្សនៈកិច្ច កម្រងផ្សេងទៀតដែលប្រតិបត្តិការងារល្អ។ សាលារៀនត្រូវចម្លងការងារនេះទៅសាលារបស់ខ្លួនពេលត្រលប់ទៅវិញ។ | ❖ ថវិកាធ្វើដំណើរអ្នកចូលរួម<br>❖ អាហារនិងភេសជ្ជៈអ្នកចូលរួម<br>(ថវិកាកណ្តាលពីអេស្កាប់) |  |
| | 22 | ❖ ការអប់រំមិនពាក់ព័ន្ធទៅនឹងតម្រូវការមូលដ្ឋាន | **ភាសាខ្មែរបន្ថែម (SKL) :** គ្រូបង្រៀនក្នុងតំបន់ភាគតិច *ទទួលបាន* ការអប់រំពិសេសដើម្បីជួយដល់ កុមារជនជាតិភាគតិចរៀនភាសាខ្មែរ និងជួយដល់ការ សិក្សារបស់គេ។ | ❖ គ្រូឧទ្ទេស<br>❖ សម្ភារបង្រៀន<br>(ថវិកាកណ្តាលពីអេស្កាប់) |  |
| | 23 | ❖ សាលារៀនមិនបានឆ្លើយតបទៅនឹងតំរូវការផ្នែកសុខភាពរបស់កុមារ | **ប្រអប់សង្គ្រោះបឋមៈ** សាលារៀនអាច *ផ្តល់* ការសង្គ្រោះបឋមដល់កុមារដើម្បីឆ្លើយតបទៅនឹងតំរូវការផ្នែកសុខភាពដែលអាចកើតមានឡើងនៅក្នុងសាលារៀន។ | ❖ សម្ភារសំរាប់សង្គ្រោះបន្ទាន់ $15/សាលា |  |

| | | | | | |
|---|---|---|---|---|---|
| | 24 | កុមារឃ្លានបាយពេលមករៀន និងមានអាហារមិនគ្រប់គ្រាន់ | **កម្មវិធីអាហារពេលព្រឹក:** ដោយស្នើទៅ WFP គណៈកម្មការសហគមន៍មូលដ្ឋាន *ផ្តល់*អាហារពេលព្រឹកដល់កុមារនៅតាមជនបទ។ | ❖ សម្ភារដាំស្ល $125/សាលា<br>❖ បណ្តុះបណ្តាលចុងភៅ $1.5/ថ្ងៃ<br>(សម្រាប់តែខេត្តកំពង់ចាម) |  |
| **សមាសភាគទី៣ ៖ សុខភាព សុវត្ថិភាព និងការការពារកុមារ** | 25 | ❖ ពិការភាពជាឧបសគ្គរារាំងមិនអោយកុមារបានចូលរៀន<br>-ពិការភាពរារាំងដល់ការចូលរៀន | **ការព្យាបាលកាយសម្បទាដល់កុមារពិការ**<br>ការអង្កេតមូលដ្ឋាន *កំណត់រក* កុមារពិការ ឬ កុមារដែលមានជំងឺ រ៉ាំរ៉ៃ និង នាំទៅកន្លែងផ្តល់សេវាព្យាបាល ។ | -អ្នកអង្កេត<br>-ថវិកាធ្វើដំណើរ<br>(ថវិកាកណ្តាលពីអេស្តាប់) |  |
| | 26 | ❖ សាលារៀនមិនបានឆ្លើយតបទៅនឹងតំរូវការផ្នែកសុខភាព របស់កុមារ | **បង្គន់អនាម័យ និងទឹកស្អាត:** សាលារៀនទាំងឡាយជីកអណ្តូង និង សាងសង់បង្គន់ដើម្បីសំរួលដល់ ការចូលរៀនរបស់កុមារី ។ | ❖ សម្ភារសាងសង់ $250/បង្គន់<br>❖ សម្ភារសាងសង់ $250/អណ្តូង |   |
| | 27 | ❖ សាលារៀនមិនបានឆ្លើយតបទៅនឹងតំរូវការផ្នែកសុខភាពរបស់កុមារ | **សួនកុមារ** សាលារៀនសាងសង់កន្លែងលេងដល់កុមារ នៅក្រោមម្លប់ឈើ ដើម្បីផ្តល់ដល់កុមារនៅឱកាសធ្វើលំហាត់ប្រាណរាងកាយ ព្រមទាំងបន្ធូរអារម្មណ៍សិក្សា។ | ❖ សម្ភារសាងសង់ $150/សាលា<br>❖ កម្លាំងពលកម្ម ពីសហគមន៍ |  |
| | 28 | ❖ សហគមន៍ពុំមានតួនាទីក្នុងការជួយទ្រទ្រង់សាលារៀន | **សាលារៀនរកកុមារ ៖** សាលារៀន និង សហគមន៍មូលដ្ឋាន *ធ្វើការអង្កេត* ដើម្បីកំណត់រកកុមារក្រៅសាលា ដោយប្រើប្រាស់ផែនទី។ កុមារទាំងនោះនឹងបានទទួលនូវសេវាពិសេសពីសាលារៀន។ ឧ. អាហារូបករណ៍ ដើម្បីអោយពួកគេបានចូលរៀន។ | ❖ អ្នកអង្កេត $1/ម្នាក់ x ៥ថ្ងៃ<br>❖ សម្ភារគូរផែនទី $10/សាលា |  |

| | | | | | |
|---|---|---|---|---|---|
| | 29 | ❖ ការរៀនមិនចប់ធ្វើអោយអត្រាបញ្ចប់ការសិក្សាមានអត្រាទាប | **គ្រូសហគមន៏:** គណៈកម្មការកំរងសាលា គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នា ជ្រើសរើសសមាជិកសហគមន៏ដើម្បធ្វើជាគ្រូនៅតាមសាលា។ គ្រូទទួលបានកម្មវិធីបំប៉នពីកម្មវិធីអេស្កាប់ ។ | ❖ គ្រូស្ម័គ្រចិត្ត<br>❖ សម្ភារសំរាប់បង្រៀន<br>❖ (ថវិកាកណ្តាលពីអេស្កាប់)<br>ដំណើរការជ្រើសរើស \$30/កម្រង |  |
| | 30 | សហគមន៏មិនមានតួនាទីនៅក្នុងសាលារៀន | **ក្រុមប្រឹក្សាគ្រូសហគមន៏:**<br>គណៈកម្មាការអប់រំសំរាប់ទាំងអស់គ្នា CEFACs *ត្រួតត្រាមើល* លើការជ្រើសរើស ការបើកលុយ និង តាមដានគ្រូសហគមន៏ ដោយសហការជាមួយនាយកសាលា។ | ❖ ផ្តល់ការបណ្តុះបណ្តាលដល់មនុស្សដែល ជាធនធាន<br>- តាមដានគ្រូសហគមន៏<br>\$1/ថ្ងៃម្នាក់ x ៣ថ្ងៃ/ខែ x ៩ខែ<br>- សម្ភារ \$15/ CEFACs |  |
| | 31 | ❖ ការអប់រំមិនពាក់ពន្ធ័ទៅនឹងតម្រូវការមូលដ្ឋាន<br>❖ សហគមន៏មិនមានតួនាទីនៅក្នុងសាលារៀន | **មណ្ឌលវប្បធមិ** សាលារៀន *រៀបចំ* បន្ទប់ពិសេស ដើម្បីផ្តល់ឱកាសដល់សិស្សបានរៀនសូត្រនូវវប្បធម៏ចំរុះនៅក្នុងសហគមនរបស់គេ។ | ❖ សម្ភារសាងសង់<br>\$500/មណ្ឌល<br>❖ វត្ថុដែលទាក់ទងនឹងវប្បធម៏ ពីសហគមន៏ |  |
| | 32 | ❖ ការអប់រំមិនពាក់ពន្ធ័ទៅនឹងតម្រូវការមូលដ្ឋាន<br>- សហគមន៏មិនមានតួនាទីនៅក្នុងសាលារៀន | **ការសិក្សាពីបំនិនជីវិតផ្នែកវប្បធម៏:**<br>ទាំងកុមារជនជាតិភាគតិច ទាំងកុមារជនជាតិភាគតិចខ្មែរ *ទទួលបាន* ឱកាសរៀនសូត្រពីវប្បធម៏ និង សាសនានៅតាមសាលារៀន។ ថ្នាក់រៀនទាំងឡាយប្រើប្រាស់អ្នករស់នៅ ក្នុងមូលដ្ឋានជាធនធានសំរាប់សិក្សា។ | ❖ សម្ភារសំរាប់បង្រៀន<br>\$100/សាលា<br>- ប្រាក់ឧបត្ថម្ភសំរាប់គ្រូ<br>\$0.5/ម៉ x ៤ម៉/សប្តាហ៏ x ១០សប្តាហ៏ |  |

| | | | | | |
|---|---|---|---|---|---|
| | | | | ❖ ប្រាក់ឧបត្ថម្ភអ្នកតាមដាន $1/សប្តាហ៏ x ១០សប្តាហ៏ | |
| | 33 | ❖ ការអប់រំមិនពាក់ពន្ធ័ ទៅនឹងតម្រូវវប្បធមិ ក្នុងមូលដ្ឋាន | **ក្រុមប្រឹក្សាកុមារ** យុវវ័យនៅតាមមូលដ្ឋាន *ទទួល* បានការគាំទ្រក្នុងការ *រៀបចំ* សហគមន៍ជំនួយដល់ការ សិក្សាពីវប្បធមិមូលដ្ឋាន (បង្រៀនកុមារ សិក្សាស្រាវជ្រាវពីវប្បធម៌នៅមូលដ្ឋាន ហើយរាយការណ៍ជូនក្រុមដែលមានស្ថានភាពប្រហាក់ប្រហែល ។ល។) | ❖ គ្រូស្ម័គ្រចិត្ត<br>❖ ថវិការសំរាប់សកម្មភាពពិសេស $150/ក្រុម |  |
| | 34 | សហគមន៍មូលដ្ឋានមិនមានតួនាទីក្នុងការអប់រំ | **ផ្សារប្រឌិត** សាលារៀនរៀបចំការបង្ហាញពិសេសមួយ ដែលផ្តល់អោយកុមារ មានឱកាសប្រើប្រាស់ ការសិក្សាបំណិនជីវិតដែលបានរៀនក្នុងឆ្នាំសិក្សា។ ការបង្ហាញនេះផ្តល់នូវឱកាសអោយសហគមន៍ចូលរួមក្នុងការអប់រំកុមារផងដែរ។ | ❖ សម្ភាររៀបចំបង្ហាញ $125/ សាលា<br>❖ អាហារនិងភេសជ្ជៈ $25/ សាលា |  |
| | 35 | សហគមន៍មូលដ្ឋានមិនមានតួនាទីក្នុងការអប់រំ | **ក្តារខៀនព័ត៌មានសម្រាប់សហគមន៍** សាលាសាងសង់ក្តារខៀនព័ត៌មាននៅក្នុងភូមិ ដើម្បីបង្កើនទំនាក់ទំនងរវាងសាលារៀននិងសហគមន៍។ ក្តារខៀននោះផ្តល់ព័ត៌មានពីដំណើរការចុះឈ្មោះចូលរៀន ព្រឹត្តិការណ៍សំខាន់ៗ រឺ ការប្រជុំឱកាសឪពុកម្តាយសិស្សមកទស្សនៈកិច្ចនៅក្នុងសាលា ...។ | ❖ សម្ភារសាងសង់ **$50/ភូមិ**<br>❖ កម្លាំងពលកម្ម ចូលរួមពីសហគមន៍ |  |

| | | | | | |
|---|---|---|---|---|---|
| សមាសភាគទី៥ : ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ | 36 | សហគមន៍មូលដ្ឋានមិនមានតួនាទីក្នុងការអប់រំ | **ការប្រជុំប្រចាំឆមាសរបស់សហគមន៍ គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ និងសាលារៀន** (ថ្នាក់កម្រង): សលារៀនរៀបចំការប្រជុំយ៉ាងហោចណាស់ ២ ដងក្នុងមួយឆ្នាំដើម្បីជួបជុំឪពុកម្តាយសិស្សពិភាក្សាស្តីពីការអប់រំនៅក្នុងសាលារៀន។ | ❖ អាហារសម្រន់និងភេសជ្ជៈ $10/ម្តង |  |
| | 37 | សហគមន៍មូលដ្ឋានមិនមានតួនាទីក្នុងការអប់រំ | **ទិវាសាលារៀន (បុណ្យសាលារៀន):** សាលារៀនរៀបចំពិធីសប្បាយរីករាយមួយនៅដើមឆ្នាំសិក្សា (មាន វីដេអូ ល្បែងប្រជាប្រិយកុមារ ការប្រកួតប្រជែងផ្សេងៗ...) ដើម្បីញាំងអោយសហគមន៍ មានចំណាប់អារម្មណ៍ក្នុងការមកចុះឈ្មោះចូលរៀន និងបង្ហាញពីតួនាទីសាលារៀននៅក្នុងសហគមន៍។ | អំណោយមួយផ្នែកតូចដល់សាលារៀន (ថវិកាកណ្តាលពីអេស្គាប់) |  |
| សមាសភាគទី៦ : ការគាំទ្រកម្រិតប្រព័ន្ធ | 38 | សោហ៊ុយធ្វើដំណើរបង្អាក់ដំណើរការប្រជុំប្រចាំកម្រង | **ការគាំទ្រផ្នែករដ្ឋបាលដល់គណៈកម្មការកម្រងសាលា :** គណៈកម្មការកម្រងផ្តល់នូវថវិកាសម្រាប់ធ្វើដំណើរដល់សមាជិក ដើម្បីធានាវត្តមានការប្រជុំប្រចាំខែ និងការងារផ្សេងទៀតនៅក្នុងកម្រង។ | -ថវិកាធ្វើដំណើររបស់សមាជិក $1.5/ម្នាក់ x ម្តង/ខែ x ៩ខែ | |
| | 39 | សាលារៀនមិនយល់ពីរបៀ | **ស្វ័យវាយតម្លៃសាលារៀន :** កម្រងជ្រើសរើស សាលា | -ថវិកាធ្វើដំណើរទៅសាលា | |

| | | | | | |
|---|---|---|---|---|---|
| | | ប វាយតម្លៃ ដើម្បីសម្រប សម្រួលកែលំអការងនុវត្ត ការ អប់រំក្នុងមូលដ្ឋាន | រៀនដែលល្អជាងគេមួយរឺពីរ ហើយរៀបចំធ្វើការវាយតម្លៃ ដោយស្មោះត្រង់ និងវាយតម្លៃវិភាគទូវការអនុវត្ត ដើម្បីកែលំអការអនុវត្តការអប់រំក្នុងមូលដ្ឋាន តាមរយៈសមាសភាគសាលាកុមារមេត្រីទាំងមូល។ | គោលដៅ $1.5/ម្នាក់ x ៣ថ្ងៃ | |
| | 40 | សាលារៀនមិនយល់ពីរបៀប វិភាគប្រសិទ្ធភាពលទ្ធផល កត្តាចង្អុលបង្ហាញសាលារៀន | **ការប្រមូលទិន្នន័យសម្រប់ធ្វើរបាយការណ៍ :** កម្រងប្រមូលនិងវិភាគទិន្នន័យ ទៅលើកត្តាចង្អុលបង្ហាញចុងក្រោយ | - ទម្រង់ប្រមូលទិន្នន័យ (ថវិកាកណ្តាលពីអេស្កាប់) | |

- សមាសភាគទី១ និងទី៤ : ពីលេខ ១-៩
- សមាសភាគទី២ : លេខ ១០-២២
- សមាសភាគទី៣ : លេខ ២៣-២៧
- សមាសភាគទី៥ : លេខ ២៨-៣៧
- សមាសភាគទី៦ : លេខ ៣៨-៤០